ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ការិយាល័យទំនាក់ទំនងពាណិជ្ជកម្មកម្ពុជា

ប្រចាំនៅទីក្រុងណាននីង

លេខ ០៧៩៣ កពណក.ណន

សូមគោរពជូន

ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**កម្មវត្ថុ: របាយការណ៍ ប្រចាំខែ មេសា ឆ្នាំ ២០១២**

សេចក្ដីដូចបានជំរាបជូនក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទមានកិត្តិយស គោរពជូន **ឯកឧត្តម ទេសរដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ប្រចាំខែ មេសា ឆ្នាំ២០១២ ដ៏ខ្ពង់ខ្ពស់ដូចតទៅ:

## I. ការងារទំនាក់ទំនងផ្សេងៗ:

- ជួបក្រុមហ៊ុន Guangxi Nanning City, Green Plant មានបំណងវិនិយោគទុនលើផ្នែកទេសចរណ៍នៅខេត្តកោះកុង ។
- ជួបសមាគម Guangxi Jewelry Assocation មានបំណងអញ្ជើញក្រុមហ៊ុនកម្ពុជាចូលរួមពិពរណ៍អលង្ការនៅណាននីងនាថ្ងៃទី១០-១៣ឧសភា ឆ្នាំ២០១២ ។
- ជួបក្រុមហ៊ុន China Youth Tranel Services មានបំណងស្វែងរកដៃគូលើវិស័យទេសចរណ៍នៅកម្ពុជា ។
- ជួបក្រុមហ៊ុន Guangxi Maofu Potato Co.,Ltd មានបំណងស្វែងរកដៃគូក្នុងការដាំដំណាំនៅកម្ពុជា ។
- ជួបក្រុមហ៊ុន Guangxi Fengze Group មានបំណងវិនិយោគទុននៅកម្ពុជា លើវិស័យសំណង់អាគារ អភិវឌ្ឍន៍ធនធានរ៉ែនិង ដីសម្បទានដាំស្រូវ និងដីដាំកូនឈើនៅកម្ពុជា ។
- ជួប Macau Union Suppliers Association មានបំណងស្វែងរកទីផ្សារអង្ករនៅកម្ពុជា ។
- ចូលរួមសិក្ខាសាលាស្ដីពីវិនិយោគលើវិស័យកសិកម្មដែលរៀបចំឡើងដោយការិយាល័យជំរុញវិនិយោគនៅណាននីង ។
- ចូលរួមកម្មវិធីសិល្បៈអាស៊ានដែលសំដែងដោយនិស្សិតអាស៊ាននៅសកលវិទ្យាល័យក្វាងស៊ីក្រុងណាននីង ។
- ជួបជាមួយក្រុមហ៊ុន CABIS មានបំណងឱ្យការិយាល័យជួយជំរុញការអនុវត្តគំរោងChina-ASEAN Plaza ។
- ចូលរួមពិពរណ៍សង្ហារិម China(Nanning) International Household and Furniture Expo ។
- ចូលរួម Fight against Pornography illegal Publication and Piracy ដែលរៀបចំឡើងដោយ

Address: No 11, Zhujin Road, China-ASEAN Business District,
Nanning City, Guangxi, China
Tel/Fax: +86-771-5389496
Email : clo cambodia@yahoo.com

មន្ទីរការបរទេសខេត្តក្វាងស៊ី ។

- ជួបក្រុមហ៊ុន Real Estate Development Industry Co.Ltd. មានបំណងវិនិយោគទុនក្នុងការសាងសង់សណ្ឋាគាថ្នាក់ផ្កាយ៥នៅកោះពេជ្រនិងស្វែងរកទីផ្សារជំឡូងនៅកម្ពុជា ។

## II. សភាពការណ៍សេដ្ឋកិច្ចនៅសាធារណរដ្ឋប្រជាមានិតចិន:

ផ្អែកតាមការសិក្សាស្រាវជ្រាវរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានឱ្យដឹងថាកំណើនសេដ្ឋកិច្ចចិនក្នុងឆ្នាំ២០១២នេះនឹងកើនបាន៨,២% ។ តាមការព្យាករIMFបានទោះទាយថានៅក្នុង ឆ្នាំ២០១៣ខាងមុខនេះសេដ្ឋកិច្ចចិននឹងកើនបាន៨,៨% ។ ជាក់ស្តែងការផ្លាស់ប្តូរពាណិជ្ជកម្មចិនប្រចាំខែមិនាឆ្នាំ២០១២កើនបានខ្ពស់ជាងខែកុម្ភៈឆ្នាំ២០១២ ដែលសំរេចបាន៥,៣៥កោដិដុល្លា ។ កំណើនការនាំចេញរបស់ចិនកើនបាន៨,៩% ដែលមានទឹកប្រាក់ ១៦៥,៦៦កោដិដុល្លា ឯការនាំចូលវិញរក្សាបានលំនឹងស្ថេរភាពដែលមានទឹកប្រាក់១៦០,៣១កោដិដុល្លា ។ ដោយឡែកគ្រោះអធិផរណាខែ កុម្ភៈ ឆ្នាំ២០១២នេះកើនឡើងខ្ពង់ជាងខែ កុម្ភៈឆ្នាំ២០១១ ដែលមានទឹកប្រាក់៣១,៤៨ កោដិដុល្លា ។ នៅក្នុងខែមីនា ឆ្នាំ២០១២គ្រោះអធិផរណាអនុវត្តបាន៣,៦កោដិដុល្លា ។ មូលហេតុនៃការកើនឡើងគ្រោះអធិផរណាដោយមានការឡើងថ្លៃប្រេងឥន្ធនៈនិងតំលៃស្បៀងអាហារ ។ ទន្ទឹមនោះសំភារៈប្រើប្រាស់ប្រចាំថ្ងៃឡើងថ្លៃ៣,៦% ។ នៅឱកាសដែលលោកខាងលិចកំពុងជំរុញកំណើនសេដ្ឋកិច្ចរបស់ខ្លួននោះក្រុមហ៊ុនវិនិយោគបរទេសធ្លាប់មកប្រទេសចិនមានការធ្លាក់ចុះ ។ ផ្អែកតាមពត៌មានដែលផ្តល់ដោយក្រសួងពាណិជ្ជកម្មចិនបានបញ្ជាក់ថានៅក្នុងខែ កុម្ភៈ ឆ្នាំ២០១២ក្រុមហ៊ុនវិនិយោគទុនបរទេស(FDI)មកប្រទេសចិនមានការធ្លាក់ចុះចំនួន០,៩%ដែលមានទឹកប្រាក់ ៧,៧៣ កោដិដុល្លាទាបជាងខែមករាៈឆ្នាំ២០១២ដែលសំរេចបានរហូតដល់១០ កោដិដុល្លា ។ អង្គការពាណិជ្ជកម្មពិភពលោកបានចុះបញ្ជីប្រទេសចិនជាប្រទេសដែលរកចំណូលពាណិជ្ជកម្មបាន ខ្ពង់ជាងគេ ។ កន្លងមក WTO បានចាត់ទុនពាណិជ្ជកម្មចិនចាត់ចំណាត់ថ្នាក់ទី២ ។ នៅក្នុងឆ្នាំ២០១១ WTO បានរកឃើញថាពាណិជ្ជកម្មក្រៅប្រទេសរបស់ចិនកើនបាន២,៩៧កោដិដុល្លាខ្ពស់ជាងឆ្នាំ២០១០ កន្លងមកចំនួន៦ដង ។ ដូច្នេះវិស័យពាណិជ្ជកម្មចិនមានតួនាទីសំខាន់ក្នុងការអភិវឌ្ឍន៍ សេដ្ឋកិច្ចជាតិ ។

សេចក្តីដូចបានជំរាបជូនខាងលើ សូម **ឯកឧត្តម ទេសរដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ប្រចាំខែមេសា ឆ្នាំ២០១២ ដោយអនុគ្រោះបំផុត ។

សូម **ឯកឧត្តម ទេសរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំបាទ ។

ក្រុងណាននីង, ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ ២០១២

ទីប្រឹក្សាពាណិជ្ជកម្ម

**អ៊ុច គីមយ៉ុន**

ចម្លងជូនៈ

-អគ្គកុងស៊ុលនៅណាននីង

-ឯកសារកាលប្បវត្តិ